# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១០៨ អយអក/០៥

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>សូមជម្រាបមក</u>**

## លោកប្រធានតុលាការកំពូល

**<u>កម្មវត្ថុ</u>**: សុំណើសុំបំភ្លឺត្រង់ចំណុច២-៣ នៃកិច្ចការប្រញាប់របស់តុលាការកំពូលលេខ០៥ ចុះថ្ងៃទី០៦-០១-២០០៥

**<u>យោង</u>**: -ពាក្យបណ្តឹងរបស់លោក កង សុខខេង ហៅ ជា សុខ ចុះថ្ងៃទី១៧-០១-០៥ ប្តឹងមកក្រសួងយុត្តិធម៌អោយជួយអន្តរាគមន៍ផ្អាកការអនុវត្តកិច្ចការប្រញាប់របស់តុលាការកំពូល ។

-សុំណុំរឿងរដ្ឋប្បវេណីអង្គសេចក្តីលេខ ៣៤៧ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលតុលាការកំពង់ចាត់ការមិនទាន់ចូលជាស្ថាពរនៅឡើយ ។

-សារាចរលេខ០៤ -ស.រ.ច ៨៤ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៨៤ របស់ក្រសួងយុត្តិធម៌ ។

-សារាចរលេខ០៥ រ.ប ៩៧ ចុះថ្ងៃទី១១ -០៤-១៩៩៧ របស់ក្រសួងយុត្តិធម៌ ។

-សេចក្តីបង្គាប់លេខ១១៧ ស.រ.រ.វ ៩៧ របស់ក្រសួងយុត្តិធម៌ ។

-លិខិតលេខ០៩/០៤ គ.ក.ន.ក.រ.ត ចុះថ្ងៃទី១០-០៣-២០០៤ របស់តុលាការកំពូល ។

-កិច្ចការ ប្រញាប់លេខ០៥ ចុះថ្ងៃទី០៦-០១-២០០៥ របស់តុលាការកំពូល ។

សេចក្តីដូចបានជម្រាបជូនតាមកម្មវត្ថុ និងយោងខាងលើនេះក្រសួងយុត្តិធម៌យល់ឃើញថាៈ ដើមបណ្តឹងក្នុងរឿងក្តីរដ្ឋប្បវេណីអង្គសេចក្តីលេខ៣៤៧ ចុះថ្ងៃទី១៧-០៣-២០០៣ ក្នុងកម្មវត្ថុបណ្តឹងលែងលះនិងត្រូវបែងចែកទ្រព្យសម្បត្តិរវាងលោក កាង ហុងខេង ហៅ ថា សុខ និងប្រពន្ធឈ្មោះលោកស្រី ស៊ុន សុគន្ធី ត្រូវបានស្ថិតក្នុងការចាត់ការរបស់តុលាការក្រុងភ្នំពេញ ហើយមិនទាន់មានជាសាលក្រម ឬ សាលដីកាសម្រេចជាស្ថាពរពីតុលាការថ្នាក់លើនៅឡើយ ។

-ចំពោះករណីពាក់ពន្ធ័ដី២ ឡូត៍ នៅភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញទំហំ ៣១៣៥៦ ម² និងទំហំ ៣៦៥៤១ ម² ដែលជាទ្រព្យសម្បត្តស្ថិតក្នុងចំណងទ្រព្យរួមក្រោយចំណងអាពាហ៍ពិពាហ៍នោះគឺជាទ្រព្យអចលវត្ថុ ត្រូវរងចាំការសម្រេចជាអង្គសេចក្តីជាស្ថាពរពីតុលាការ ដែលមិនអាចអោយភាគីណាតែម្ខាងនៃសហព័ន្ធអាចចាត់ចែង លក់ដូរ ផ្ទេរ ឬ ធ្វើកិច្ចសន្យាល បញ្ចាំ ដែលធ្វើអោយបាត់ស្ថានភាពដើមបានឡើយ ។

-យោងតាមច្បាប់ សារាចរ សេចក្តីណែនាំ និងលិខិតបទដ្ឋាន ដូចមានយោងខាងលើ និងយុត្តិសាស្ត្រក្នុងការអនុវត្តរយៈពេលកន្លងមករបស់តុលាការគ្រប់ថ្នាក់ គឺការសម្រេចជាវិធានការប្រញាប់ និងបណ្តោះអាសន្នត្រូវគោរពគោលការណ៍ដូចតទៅ ៖

-រក្សាស្ថានភាពដដែលដូចពេល មិនទាន់ប្តឹងគ្នា ។

-ជាវិធានការបណ្តោះអាសន្នរង់ចាំការសម្រេចដល់អង្គសេចក្តីជាស្ថាពរ ។

-មិនប៉ះពាល់អង្គសេចក្តី ។

-មិនធ្វើអោយខូចប្រយោជន៍ដល់ភាគីណាមួយ មុនអង្គសេចក្តីចូលជាស្ថាពរ។

-មិនត្រូវដកហូតទ្រព្យសម្បត្តិពីភាគីម្ខាង ដែលកំពុងកាន់កាប់អោយទៅភាគីម្ខាងទៀតកាន់កាប់ទេ ។ ក្នុងករណីនេះដើម្បីឱ្យក្រសួងមានលទ្ធភាពឆ្លើយតបទៅម្ចាស់បណ្តឹងវិញ ក្រសួងសូមឯកឧត្តមមេត្តាបំភ្លឺមកក្រសួង និងសូមឱ្យលោកព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញរង់ចាំការឆ្លើយបំភ្លឺសិន ដើម្បីធានាឱ្យការអនុវត្តន៍កិច្ចការប្រញាប់នេះមានអនុភាពអនុវត្តន៍ទៅតាមផ្លូវច្បាប់ ។

សូមឯឧត្តមប្រធានតុលារការកំពូលមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍានា**

ចម្លងជូន

-លោកប្រធានតុលាការក្រុងភ្នំពេញ

-លោកព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ

-ម្ចាស់បណ្តឹង

-ដើម្បីជូនជ្រាប